# សម្ភារៈអប់រំបរិស្ថាន
# សម្រាប់សាលារៀន

MINISTRY FOR FOREIGN AFFAIRS OF FINLAND

ADB










## ១. អំពីផ្ទាំងផ្ទត់រូបភាព

ផ្ទាំងផ្ទត់រូបភាពនេះត្រូវបានរៀបចំសម្រាប់គ្រូ និងអ្នកសម្របសម្រួលយកមកប្រើប្រាស់នៅក្នុងពេលបង្រៀន និងរៀនពីបរិស្ថាន។

ផ្ទាំងផ្ទត់រូបភាពមាន៦ផ្នែក: ១.ធាតុអាកាស២.ទឹកនិងអនាម័យ៣.សំណល់និងអនាម័យ៤.ថាមពល៥.ជីវៈចម្រុះនិងការអភិរក្ស និង៦.ជម្រើសមុខរបរ ។ផ្នែកនីមួយៗមាន៣ទំព័រ ។ទំព័រដំបូងបង្ហាញទ្រឹស្តីទូទៅដែលជាព័តិមានដំបូងសម្រាប់គ្រូនិង២ទំព័របន្ទាប់បង្ហាញពីសកម្មភាព ដែលទាក់ទងទៅនឹងប្រធានបទនោះ ព្រមទាំងរយៈពេលជាក់លាក់មួយដើម្បីអនុវត្តទៅលើសកម្មភាពនីមួយៗ។

- នៅគ្រប់ទំព័រមុខ មានរូបភាព និង ចំណងជើងដើម្បីឱ្យសិស្សមើល ជាមួយនឹងដ្យាក្រាមលើទំព័របង្ហាញពីសកម្មភាពផងដែរ ។
- នៅគ្រប់ទំព័រក្រោយ គឺជាវត្ថុបំណងនៃមេរៀននីមួយៗ ដែលជាព័តិមានជួយដល់អ្នក។ ព័តិមាននេះក៏ផ្តល់ឱ្យចំណេះដឹងទូទៅមួយចំនួនចំពោះអ្នកសម្របសម្រួលផងដែរ ។អ្នកសម្របសម្រួលអាចប្រើប្រាស់ព័តិមានទាំងនេះដើម្បីពិភាក្សាប៉ុន្តែមិនមែនមានន័យថាអានឱ្យតែឮនោះទេ។ ជាមួយគ្នានេះ ក៏មានចំណុចពិភាក្សាមួយចំនួនដែលអ្នកត្រូវអាន ដើម្បីបង្កើតឱ្យមានការពិភាក្សាក្នុងថ្នាក់រៀន។

**គន្លឹះ**

ដើម្បីឱ្យការបង្រៀនមានភាពងាយស្រួល នៅលើទំព័រនីមួយៗមានសញ្ញាសំគាល់ :

 សញ្ញានេះ មានន័យថា គ្រប់ចំណុចពិភាក្សា និងសំណួរទាំងអស់ អ្នកសម្របសម្រួលត្រូវអាននិងពិភាក្សាជាមួយសិស្ស ។

 សញ្ញានេះ សម្រាប់សំគាល់ដល់សិស្ស ដើម្បីកាត់ត្រានៅលើផ្ទាំងក្រដាសធំ

 សញ្ញា ខ្លឹមសារត្រូវផ្តល់ឱ្យសិស្ស ។

## ២. មុនពេលចាប់ផ្តើម

- មុនពេលចាប់ផ្តើម គ្រូគួរអាន និងបន្សាំខ្លួនជាមួយនឹងផ្ទាំងផ្ទត់រូបភាពជាមុន ។ ត្រូវឱ្យច្បាស់ខ្លួនឯងថា អ្នកមានសម្ភារចាំបាច់គ្រប់គ្រាន់ ដើម្បីអនុវត្តមេរៀននេះ ។
- រៀបចំសិស្សអង្គុយរាងជាចំណិតខែនៅជុំវិញផ្ទាំងផ្ទត់រូបភាពនេះ ។ ដើម្បីឱ្យពួកគេងាយមើលឃើញច្បាស់ ។

## ៣. ពេលអនុវត្ត

- ដំបូងពិភាក្សាលើរូបភាព រួចទើបផ្តល់នូវទ្រឹស្តី ដែលពាក់ព័ន្ធ ។
- ធ្វើសកម្មភាពសប្បាយៗ និងរៀបចំការអនុវត្តជាក់ស្តែង ដែលអ្នកចូលរួមអាចធ្វើទៅបាន និងអាចចាំបានច្រើន ។
- ព្យាយាមធ្វើឱ្យអ្នកចូលរួមគ្រប់គ្នាបានអនុវត្ត ព្រោះប្រសិនបើពួកគេចាប់អារម្មណ៍នៅក្នុងសកម្មភាពណាមួយ នោះពួកគេនឹងមានការចូលរួមជាក់ជាមិនខាន ។

បោះពុម្ពដោយអង្គការ អប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live & Learn)
ផ្ទះលេខ៣២ សង្កាត់បឹង កក់ ២ ខ័ណ្ឌ ទួល គោក រាជធានីភ្នំពេញ, កម្ពុជា
ប្រអប់សំបុត្រ P.O Box 91 ទូរស័ព្ទលេខ (៨៥៥) ២៣ ៨៨៥ ៥០២
អ៊ីម៉ែល: livelearn@online.com.kh

ខែ ឧសភា ២០០៩

រៀបចំដោយ អង្គការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន
ឯកភាពដោយ ក្រសួងអប់រំយុវជន និងកីឡា
ត្រួតពិនិត្យដោយ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ

ការចេញផ្សាយនេះគឺជាផ្នែកមួយ នៃគំរោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប (TSSLP)
និងផ្តល់មូលនិធិដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB Loan 0034/0035 CAM(SF) component 3C)/
ការអប់រំដើម្បីការពារធនធានធម្មជាតិ ។

ឯកសារនេះ ប្រើសំរាប់គោលបំណងនៃការអប់រំតែប៉ុណ្ណោះ ។ បើត្រូវប្រើ សូមលើពីប្រភពរបស់វាផង ។ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកនាយក លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ នៅសាលាបឋមសិក្សានៃឃុំឆ្នុកទ្រូ និងឃុំកំពង់លួង ជាពិសេសអាជ្ញាធរមូលដ្ឋាន ដែលបានជួយយើងខ្ញុំក្នុងការសាកល្បងចំពោះសម្ភារៈមួយចំនួន ។

Published by Live & Learn Environmental Education: 32 Street 586, Sang Kat Boeung Kak 2, Khan Toul Kok, Phnom Penh, Cambodia PO Box: 91 Phone: 855 023 885502 Email: livelearn@online.com.kh http://www.livelearn.org

May 2009

Written by: Live & Learn Environmental Education
Endorsed by: Ministry of Education Youth and Sport
Proofed by: Department of Pedagogical Research
Illustrations by: Grand Arts Publishing and Karen Young

This publication forms part of the Tonle Sap Sustainable Livelihoods Project (TSSL) funded by ADB Grant No. 0034/0035 - CAM (SF) Component 3C – Educate for Protection of Natural Resources

This text is reusable for educational purposes only. If used, please cite the source.

We would like to thank the principal, teachers and students of Chhnok Trou and Kampong Luong Primary Schools for their assistance in testing these materials and also the local authorities in these areas.



# មាតិកា



### ផ្នែកទី ១ : ធាតុអាកាស

- មេរៀនស្តីពីធាតុអាកាស (ទ្រឹស្តី) ៤
- ស្ថានីយ៍ត្រួតពិនិត្យធាតុអាកាស (សកម្មភាព) ៦
- ការត្រងទឹកភ្លៀង (សកម្មភាព) ៨



### ផ្នែកទី ២ : ទឹក និងអនាម័យ

- មេរៀនស្តីពីទឹក និងអនាម័យ (ទ្រឹស្តី) ១០
- ការធ្វើតេស្តវាស់គុណភាពទឹក (សកម្មភាព) ១២
- ស្ទឹងទទួលរងការបំពុល និងស្ទឹងមានបរិស្ថានល្អ (សកម្មភាព) ១៤



### ផ្នែកទី ៣ : សំណល់ និងអនាម័យ

- មេរៀនស្តីពីសំណល់ (ទ្រឹស្តី) ១៦
- ការចូលរួមគ្រប់គ្រងសំណល់តាមសាលា ការពុកផុយសំណល់ ប្រើប្រាស់សំណល់ឡើងវិញ និងការកែច្នៃឡើងវិញ (សកម្មភាព) ១៨
- សកម្មភាពសិស្សគ្រប់គ្រងសំណល់: ការធ្វើថង់យួរ (ថង់កំណាត់) ការធ្វើជីកំប៉ុស្ត យុទ្ធនាការគ្រប់គ្រងសំណល់ (សកម្មភាព) ២០



### ផ្នែកទី ៤ : ថាមពល

- មេរៀនស្តីពីថាមពល (ទ្រឹស្តី) ២២
- សម្រង់មតិស្តីពីការប្រើប្រាស់ថាមពល (សកម្មភាព) ២៤
- ថាមពលម៉ាញេទិច ថាមពលកែវពង្រីក និងការប្រែក្លាយសំណល់ទៅជាជីវឧស្ម័ន (សកម្មភាព) ២៦



### ផ្នែកទី ៥ : ជីវៈចម្រុះ និងការអភិរក្ស

- មេរៀនស្តីពីជីវៈចម្រុះ (ទ្រឹស្តី) ២៨
- ធម្មជាតិ និងការផ្លាស់ប្តូរ: ការសម្ភាសជាមួយចាស់ៗ ការនេសាទហួសកំរិត និងរឿងស្តីពីការនេសាទហួសកំរិត (សកម្មភាព) ៣០
- ការបាត់បង់ជម្រក: ការថយចុះនៃខ្សែអាហារ ការប្រៀបធៀបផែនទី (សកម្មភាព) ៣២



### ផ្នែកទី ៦ : ជម្រើសមុខរបរ

- ធនធានសហគមន៍ (ទ្រឹស្តី) ៣៤
- ទឹក និងសុខភាព (សកម្មភាព) ៣៦
- ការរំលឹកឡើងវិញ និងការលេងល្បែងកំសាន្ត (សកម្មភាព) ៣៨






# បង្កើនសកម្មភាពរីករាយក្នុងសាលារៀន






រយៈពេល ៤០ នាទី

# ទ្រឹស្តី ៖ ធាតុអាកាស

ផ្នែក ១

វត្ថុបំណង ៖ ដើម្បីឱ្យមានការយល់ដឹងពីអាកាសធាតុ និងរដូវកាល ប្រយោជន៍ដើម្បីត្រៀមខ្លួនទាញយកទឹកភ្លៀងទុកប្រើប្រាស់ឱ្យបានយូរអង្វែង ។

## សេចក្តីផ្តើម

ធាតុអាកាសជាពាក្យទូទៅមួយ ដែលបង្ហាញពីបរិយាកាសផែនដីក្នុងរយៈពេលខ្លីមួយ (មិនលើសពី៤៨ម៉ោង) ។ កត្តាជាច្រើនដែលអាចធ្វើឱ្យអាកាសធាតុមានការប្រែប្រួលដូចជា សីតុណ្ហភាព ទឹកភ្លៀង សំពាធខ្យល់ សំណើមពេលមានពន្លឺថ្ងៃ ប្រភេទពពក និងបរិមាណនៃការគ្របដណ្តប់របស់ពពក ។ ព្រះអាទិត្យ ជាកត្តាចំបង ដែលធ្វើឱ្យធាតុអាកាសមានការប្រែប្រួល កំដៅព្រះអាទិត្យធ្វើឱ្យធាតុអាកាសមានការប្រែប្រួល ព្រោះកំដៅព្រះអាទិត្យអាចបណ្តាលឱ្យមានរំហួតទឹក ដែលអាចបង្កើតជាភ្លៀង ។

សកម្មភាពខាងក្រោម នឹងជួយយើងឱ្យមានការយល់ដឹងច្រើន ពីធាតុអាកាស ដោយធ្វើការពិនិត្យទៅលើកត្តាសំខាន់ៗមួយចំនួន ដែលមានឥទ្ធិពលដល់ធាតុអាកាស ។ ប្រការសំខាន់ ការវាស់ធាតុអាកាសត្រូវធ្វើនៅពេលវេលាដូចគ្នា តាមថ្ងៃនីមួយៗ ដើម្បីឱ្យសិស្សអាចប្រៀបធៀបគ្នាបាន ។ ហេតុនេះ ការកំណត់ពេលវេលា គឺជាជំហានដំបូង ។

សកម្មភាពបន្ទាប់ ត្រូវពិនិត្យថាតើធាតុអាកាសនោះ មានឥទ្ធិពលមកលើជីវិតប្រចាំថ្ងៃរបស់ពួកយើងយ៉ាងដូចម្តេចខ្លះ ។ ដូចជាវត្ថុមាននៃទឹកប្រើប្រាស់ដែលជាធនធានមានតម្លៃបំផុតសម្រាប់មនុស្សសត្វ ។ សិស្សានុសិស្សទាំងអស់អាចចូលរួមធ្វើសកម្មភាពផ្សេងៗ ដែលបានរៀបចំឡើងក្នុងគោលបំណងទាញយកអត្ថប្រយោជន៍ទឹកភ្លៀងស្អាត សម្រាប់ប្រើប្រាស់ពេញមួយឆ្នាំ ។

## រដូវ

ប្រទេសកម្ពុជាមានរដូវពីរគឺ- រដូវវស្សា និងរដូវប្រាំង ។

រដូវប្រាំងចាប់ផ្តើមពីខែវិច្ឆិកាដល់ខែមេសា ។ អំឡុងពេលនោះ មានភ្លៀងតិចបំផុត និងមានសីតុណ្ហភាពខ្ពស់បំផុតនៅខែ មិនា ដល់ ខែ ឧសភា (អាចឡើងដល់ 95°F (35°C)) ពិសេសនៅភាគខាងត្បូង និងភាគកណ្តាលនៃប្រទេស ។ រដូវរងារកម្រនឹងធ្លាក់ចុះក្រោម 50°F (10°C) ។ ខែវិច្ឆិកា ដល់ ខែមករា មានភាពត្រជាក់ជាងគេ ។ ខែកុម្ភៈ ដល់ខែមេសា ជាខែដែលក្តៅ និងមានខ្យល់បក់ ។ ខែវិច្ឆិកាគឺជាខែដែលត្រជាក់ជាងគេ ហើយខែមេសាជាខែដែលក្តៅជាងគេ ។

រដូវវស្សាចាប់ផ្តើមពីខែឧសភា ដល់ខែតុលា ដែលមានខ្យល់មូសុងបក់ពីទិសនិរតី ។ រដូវវស្សានាំមកជាមួយនូវទឹកភ្លៀងប្រចាំឆ្នាំប្រមាណ ៧៥% ។ ខែកក្កដា ដល់ខែកញ្ញា គឺជាខែដែលមានភ្លៀងច្រើនជាងគេ ។ ជាញឹកញាប់នៅទីខ្លះនៃប្រទេសកម្ពុជានៅចុងខែកក្កដា និងដើមខែសីហាអាចមានទឹកជំនន់កើតឡើង ។

អាកាសធាតុប្រទេសកម្ពុជា ទាក់ទងនឹងខ្យល់មូសុង ។ ទឹកភ្លៀងមានធ្លាក់ខ្លាំងនៅភាគអាគ្នេយ៍ និងតំបន់ឆ្នេរតាមជួរភ្នំ ។ សំណើមនៅពេលថ្ងៃមានជិត ៦0% និងនៅពេលល្ងាចជាទូទៅមាន៩0% ។ (ផ្ទាំងផ្ទត់រូបភាពចាស់សម្រាប់សាលារៀន) ។

## បម្រែបម្រួលអាកាសធាតុធ្វើឱ្យមានផលប៉ះពាល់ដល់កសិកម្ម

ជួនកាលនៅក្នុងរដូវវស្សាមានទឹកច្រើនលើសលប់ ហើយនៅក្នុងរដូវប្រាំងវិញមានទឹកតិចតួចប៉ុណ្ណោះ ព្រោះទឹកអណ្តូង ទន្លេ ស្ទឹង បឹង បួរ ព្រែក ប្រឡាយ ចាប់ផ្តើមគោកម្តងបន្តិចៗ អូរក្លាយជាទឹកកខ្វក់ ។ ពេលនោះសំណល់គឺជាបញ្ហាធំមួយ ដែលបានកើតមានឡើង ។ ជួនកាលគ្មានទឹកប្រើប្រាស់គ្រប់គ្រាន់នៅដូវប្រាំង ។

ផលិតផលស្បៀងអាហាររបស់ប្រទេស អាចងាយទទួលរងគ្រោះខ្លាំងពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទាំងនេះ ដូចជា គ្រោះរាំងស្ងួត និងទឹកជំនន់ ។ ធាតុអាកាស អាកាសធាតុ និងអាចមានផលប៉ះពាល់ខ្លាំងទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។ ការអង្កេតយ៉ាងជាក់លាក់ និងការទស្សទាយពីធាតុអាកាស អាកាសធាតុ និងទឹក សុទ្ធជាកត្តាសំខាន់ ។

ប្រជាជនកម្ពុជាពឹងផ្អែកមួយខ្លាំង ទៅលើធនធានធម្មជាតិ ក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ខ្លួន ។ យោងតាមរបាយការណ៍UNDPចំនួនបួននាក់ក្នុងចំណោមប្រជាជនកម្ពុជា ៥ នាក់ប្រកបរបរចិញ្ចឹមជីវិតដោយពឹងអាស្រ័យផ្ទាល់ ពី ទឹក ត្រី និងព្រៃឈើ ។ លក្ខខណ្ឌធាតុអាកាស ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើកសិកម្ម ។ដំណាំកសិកម្មបានទទួលជោគជ័យឬបរាជ័យ អាស្រ័យលើធាតុអាកាស ព្រោះភ្លៀងច្រើនពេកអាចធ្វើឱ្យលិចដំណាំ តែបើភ្លៀងតិចពេកធ្វើឱ្យរាំងស្ងួះ ដល់ការលូតលាស់ ។ ក្នុងការដាំដំណាំកសិករត្រូវគិតមុនដំបូងគេ អំពីអាកាសធាតុ និងរដូវកាលបន្ទាប់មកជ្រើសរើសដំណាំដើម្បីដាំទៅតាមរដូវកាល ។

ជាភស្តុតាងស្រាប់នៃសកម្មភាពរបស់មនុស្សមួយចំនួន ជាពិសេស ការផលិតសារជាតិឧស្ម័នកាបូនិចជាច្រើន ធ្វើអោយប៉ះពាល់ដល់រដូវកាលដែលជាផ្នែកមួយនៃធាតុ អាកាសដែលហៅថាបំរែបំរួលអាកាសធាតុ ។ បំរែបំរួលអាកាសធាតុធ្វើអោយមាន ការពិបាកក្នុងការទស្សទាយទុកជាមុននូវពេលវេលាក្នុងការដាំដុះស្រែចំការ ។ ផលិតផលស្រូវអាចនឹងទទួលរងផលប៉ះពាល់ដោយសាររដូវកាលនៃការលិចលង់ និងរាំងស្ងួតមានសភាព កាន់តែខ្លាំងក្លាឡើង ។

## ធាតុអាកាស និងវដ្តទឹក

បញ្ហាដ៏សំខាន់មួយនៃធាតុអាកាស គឺភ្លៀង ។ ភ្លៀងគឺជាផ្នែកមួយនៃ វដ្តទឹក ជាដំណើរវិលចុះឡើងនៃទឹក ។ ភ្លៀងអាចធ្លាក់គ្រប់ទិសទី ហើយទឹកភ្លៀងអាចជ្រាបចូលទៅក្រោមដីហើយក្លាយទៅជាទឹកក្រោមដី រឺហូរចូលស្ទឹងបឹងបួរ ទន្លេ ព្រែក អូរ ប្រឡាយ និងមហាសមុទ្រ ។ មហាសមុទ្រ ទន្លេ និងផែនទឹកកកជាកន្លែងផ្ទុកទឹកដ៏សំខាន់ ។ ទឹកនៅផ្ទៃខាងលើត្រូវកំដៅព្រះអាទិត្យ ត្រូវហួតទៅក្នុងលំហអាកាសដែលហៅថា រំហួត រីឯសំណើមនៅក្នុងរុក្ខជាតិត្រូវកំដៅហើយហួតឡើងទៅលើតាមរយៈការបំភាយ ។ ទឹកដែលឡើងទៅក្នុងលំហអាកាស បង្កើតបានជាពពក ហើយដែលជាដំណើរការវដ្តទឹក ។

## ទឹកដែលអាចប្រើប្រាស់បាន

ប្រហែលជា៩៧% នៃបរិមាណទឹកទាំងអស់ នៅលើភពផែនដីជាទឹកប្រៃ ។ ជាទូទៅមនុស្សមិនអាចប្រើប្រាស់ទឹកនេះ សម្រាប់ហូប ដាំដុះ ឬប្រើក្នុងគោលបំណងនៃឧស្សាហកម្មបានឡើយ ។ បរិមាណ៣% នៃទឹកលើផែនដី គឺជាទឹកសាប ។ ទឹកសាបជាច្រើនបានក្លាយជាដុំទឹកកកនៅតំបន់ប៉ូល ឬក៏មាននៅក្រោមដីដ៏ជ្រៅ ដែលយើងមិនអាចយកមកប្រើប្រាស់បាន ។ ទឹកសាបតិចតួចបំផុតប្រហែល 0.00៣% នៅលើផែនដីគឺជាទឹកសាបដែលមនុស្សអាចយកមកប្រើប្រាស់បាន ។ វត្ថុមាននៃទឹកនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងធាតុអាកាស ពីព្រោះទឹកភ្លៀង និងទឹកនៅលើផ្ទៃដីផ្តល់ឱ្យនូវប្រភពទឹក ដ៏សំខាន់សម្រាប់យកមកប្រើប្រាស់ ។យើងទាំងអស់គ្នាថែរក្សាធនធានទឹកសាបរបស់យើង ។ ដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតយើងចាំបាច់ត្រូវថែរក្សាទឹកនោះកុំឱ្យកខ្វក់ឬមិនមានបំពុល ឬមួយឆ្លងមេរោគឡើយ ហើយត្រូវប្រើប្រាស់វាដោយសន្សំសំចៃ (កុំខ្ជះខ្ជាយ) ។ មានវិធីសាស្ត្រជាច្រើន ដែលមនុស្សអាចថែរក្សាទឹកឱ្យបានល្អថែមទៀត ។ (សៀវភៅណែនាំសំរាប់អ្នកអប់រំបរិស្ថាន)

## ការត្រងទឹកភ្លៀង

តើការត្រងទឹកភ្លៀងមានន័យយ៉ាងដូចម្តេច?

ការត្រងទឹកភ្លៀងមានន័យថាត្រងទឹកភ្លៀងនៅកន្លែងដែលមានភ្លៀងធ្លាក់ឬត្រងយកពីដំបូលផ្ទះក្នុងភូមិរបស់យើង ហើយរក្សាទុកដើម្បីប្រើ ។ ទឹកភ្លៀងគឺជាប្រភពដំបូង ដែលបានមកពីវដ្តទឹក ។ ដូច្នេះ វាជាប្រភពដំបូងរបស់ទឹកទី ១ សម្រាប់យើងប្រើប្រាស់ ។ ទន្លេ បឹង និងទឹកក្រោមដី ទាំងអស់ គឺជាប្រភពទឹកទីពីរសម្រាប់យើងប្រើប្រាស់ ។

យើងចាំបាច់ត្រូវតែយល់ដឹងពីអាកាសធាតុ ដើម្បីរៀបចំផែនការត្រងទឹកភ្លៀង ។ នៅរដូវវស្សា យើងអាចត្រងទឹកភ្លៀងទុកក្នុងធុងបានច្រើន ។ បើសិនយើងសំអាតដំបូលផ្ទះ ឬធុងរបស់យើង នោះទឹកភ្លៀងក៏ស្អាតទៅតាមហ្នឹងដែរ ហើយវាក៏ជាប្រភពទឹកដ៏ល្អបំផុត សម្រាប់ប្រើប្រាស់ផងដែរ ។ ទឹកភ្លៀងស្អាតអាចយកមកផឹកបានដោយមិនចាំបាច់ដាំឡើយ ។

ទឹកភ្លៀង មានភាពកខ្វក់និងការឆ្លងមេរោគតិចជាងទឹកទន្លេនិងបឹង ។ ការប្រើប្រាស់ទឹកភ្លៀងសម្រាប់ផឹក (លើកលែងតែភ្លៀងអាស៊ីត) គឺជាជម្រើសដ៏ល្អបំផុតសម្រាប់សុខភាពហើយអាចចៀសវាងនូវជម្ងឺជាច្រើនដូចជាជម្ងឺរាក និងជម្ងឺធ្ងន់ធ្ងរផ្សេងទៀតដែលអាចបណ្តាលឱ្យស្លាប់ ។

វាពិតជាមានអត្ថប្រយោជន៍ខ្លាំងណាស់ ប្រសិនបើយើងអាចថែរក្សាទឹកភ្លៀងបានរហូតដល់រដូវប្រាំង ។ នៅរដូវប្រាំង យើងតែងជួបការលំបាកក្នុងការស្វែងរកទឹកប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ ជាពិសេសក្នុងសហគមន៍ដាច់ស្រយាល ។ នៅរដូវនេះ ប្រភពទឹក ក៏មានភាពកខ្វក់ណាស់ដែរ ។ ដូច្នេះនៅរដូវវស្សា យើងត្រូវត្រងទឹកភ្លៀងឱ្យអស់ពីលទ្ធភាព បើអាចធ្វើបាននិងប្រើប្រាស់ទឹកភ្លៀង ។ ទឹកភ្លៀងគួរតែប្រើសម្រាប់តែផឹក ពីព្រោះ ទឹកដែលមិនសូវមានសុវត្ថិភាព យើងអាច ប្រើសម្រាប់ចំអិនអាហារ ឬក៏ដុសលាង ។




## ចំណុចពិភាក្សា

ក. តើវត្ថុបំណងនៃរូបភាពនេះចង់និយាយពីអ្វី?

ខ. ហេតុអ្វីបានជាធាតុអាកាស (សីតុណ្ហភាព ខ្យល់ និង ភ្លៀង) មានសារៈសំខាន់ ?

គ. តើធាតុអាកាសមិនល្អ បណ្តាលឱ្យមានផលប៉ះពាល់អ្វីខ្លះ?

ឃ. តើវដ្តទឹកជាអ្វី? ហេតុអ្វីបានជាទឹកភ្លៀងមានសារៈសំខាន់?

ង. តើក្នុងតំបន់របស់អ្នកមានរដូវអ្វីខ្លះ? ហេតុអ្វីបានជាការស្គាល់រដូវកាលមានសារៈសំខាន់សម្រាប់យើង?

ច. ហេតុអ្វីបានជាទឹកភ្លៀងល្អមានសុវត្ថិភាពជាងទឹកស្ទឹងឬទឹកអណ្តូង?

ឆ. តើអ្នកអាចប្រើប្រាស់ទឹកភ្លៀងឱ្យបានយូរដោយវិធីណា?


សីតុណ្ហភាព (°C) ទឹកភ្លៀង (mm)
៣០០
២៥០
២០០
១៥០
១០០
៥០
0
មករា កុម្ភៈ មិនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា តុលា វិច្ឆិកា ធ្នូ
ជាមធ្យម សីតុណ្ហភាពប្រចាំថ្ងៃ (អប្បបរមា)
ជាមធ្យម សីតុណ្ហភាពប្រចាំថ្ងៃ (អតិបរមា)
ទឹកភ្លៀង


ការប្រែប្រួលអាកាសធាតុ
និងកំរិតទឹកបឹងទន្លេសាប
តំបន់លិចទឹកជាប្រចាំ
តំបន់លិចទឹកនៅតាមរដូវកាល


ដំបូលស្អាត
ទរបង្ហូរទឹក
បន្ទះបិទបើក
គំរបពាង


ការរំហួត
កំណកញើស និងភ្លៀង
ការបំភាយចំហាយទឹក
ទឹកហូរ ការជ្រាបទឹក
និងការជ្រាបទឹកចូលក្រោមដី



